ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ


ការិយាល័យទំនាក់ទំនងពាណិជ្ជកម្មកម្ពុជា
ប្រចាំនៅទីក្រុងណាននីង


លេខ 00/143 កពណក.ណន

**សូមគោរពជូន**

**ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**<u>កម្មវត្ថុៈ</u> របាយការណ៍ ប្រចាំខែតុលា ឆ្នាំ២០១២**

សេចក្តីដូចបានជំរាបជូនក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទមានកិត្តិយសសូមគោរពជូន **ឯកឧត្តមទេសរដ្ឋមន្ត្រី** មេត្តាជ្រាបនូវរបាយការណ៍ប្រចាំ ខែតុលា ឆ្នាំ២០១២ ដ៏ខ្ពង់ខ្ពស់ដូចតទៅ ៖

## I. <u>ការងារទំនាក់ទំនងជាមួយភ្ញៀវ</u>

- ជួបទស្សនាវដ្តី XIE ZHUZHENGFU FUWUQIYE មានបំណងស្វែងយល់ក្រុមហ៊ុនប្រេងឥន្ធនៈនៅកម្ពុជា ដើម្បីផ្សព្វផ្សាយ ។
- ជួបពាណិជ្ជករចិនមានបំណងទិញអង្ករពីកម្ពុជានិងនាំចូលសំភារៈប្រើប្រាស់ប្រចាំថ្ងៃ ។
- ជួបនិងទស្សនកិច្ចឃ្លាំងស្តុកកសិផលរបស់ក្រុមហ៊ុន GuangxiGuohong Development Cooperation ក្នុងការកែឆ្នៃ វូចនាំចេញទៅកាន់ទីផ្សារនៅប្រទេសចិន ។
- ជួបក្រុមហ៊ុនផលិតថង់ប្លាស្ទិកនៅ Liuzhou មានបំណងស្វែងយល់បែបបទក្នុងការវិនិយោគទុននៅកម្ពុជា ។
- ជួបក្រុមហ៊ុន Guangxi Construction Engineering Group Co.,Ltd. មានបំណងវិនិយោគទុនក្នុងការសាងសង់ផ្លូវថ្នល់នៅកម្ពុជា ។
- ជួបក្រុមហ៊ុន Guangxi Nanning Longli Energy Technology Co., Ltd. មានបំណងវិនិយោគទុនក្នុងការតំលើងរោងចក្រផលិតអាល់កុល (Alcohol)នៅកម្ពុជាដោយប្រើប្រាស់ដំឡូងជាមូលដ្ឋាន ។
- ទស្សនកិច្ចសិក្សាស្រាវជ្រាវរោងចក្រផលិត Alcohol អំពីអំពៅនៅក្រុង ប៉ៃស៊ី (Baise) ខេត្ត ក្វាងស៊ី ។
- ទស្សនកិច្ចសិក្សានៅសហគ្រាសគីមីកសិកម្ម និងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលរៀបចំឡើងដោយមន្ទីរការបរទេស ខេត្តក្វាងស៊ី ។
- ជួបក្រុមហ៊ុន Huakang Electrical Equipment មានបំណងស្វែងរកច្បាប់វិនិយោគនៅកម្ពុជា ។

## II. សភាពការណ៍សេដ្ឋកិច្ចនៅសាធារណរដ្ឋប្រជាមានិតចិន

ការស្ថាបនាតំបន់ឆ្លងកាត់សេដ្ឋកិច្ចរវាង **ចិននិងអាស៊ាន** ជាគំនិតនៃរបៀបវារៈនៃកិច្ចប្រជុំនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២ នៅឱកាសពិពរណ៍ពាណិជ្ជកម្មអន្តរជាតិ CAEXPO លើកទី៩ នៅក្រុងណាននីង ។ ចាប់ពីការបង្កើត


Address: No 11, Zhujin Road, China-ASEAN Business District, Nanning City, Guangxi, China
Tel/Fax : +86-771-5389496
Email : clo_cambodia@yahoo.com

តំបន់ពាណិជ្ជកម្មសេរីចិន-អាស៊ាន (CAFTA) នៅក្នុងខែមករា ឆ្នាំ២០១០មក គេសង្កេតឃើញថាការទំនាក់ទំនងពាណិជ្ជកម្មនិងវិនិយោគ រវាងខេត្តក្វាងស៊ីនិងអាស៊ានមានការកើនឡើងគួរឱ្យកត់សំគាល់ ។ រយៈកាលកន្លងមកអាស៊ានជាប្រភពវិនិយោគធំជាងគេ និងជាដៃគូពាណិជ្ជកម្មសំខាន់បំផុតរបស់ខេត្តក្វាងស៊ី ។ ជាក់ស្តែងនៅឆ្នាំ២០០៤កន្លងទៅការផ្លាស់ប្តូរពាណិជ្ជកម្ម រវាងក្វាងស៊ី និងអាស៊ានកើនបានតែ ១កោដិដុល្លាអាមេរិក ដោយឡែកនៅក្នុងឆ្នាំ២០១១កើនបានរហូតដល់ ៩,៥កោដិដុល្លាអាមេរិក ។ ការផ្លាស់ប្តូរពាណិជ្ជកម្មសរុបរបស់ក្វាងស៊ី ក្នុងឆ្នាំ២០១១ជាមួយប្រទេសអាស៊ានសំរេចបាន ៤១% ខ្ពស់ជាងឆ្នាំ២០០៤ ដែលសំរេចបានតែ ២៣% តែប៉ុណ្ណោះ។ អស់រយៈពេល១២ឆ្នាំកន្លងមកអាស៊ានជាដៃគូពាណិជ្ជកម្ម ជាមួយខេត្តក្វាងស៊ីចាត់ចំណោត់ថ្នាក់ទី១ ។ ដោយឡែករយៈកាលកន្លងមកអាស៊ានបានវិនិយោគនៅខេត្ត ក្វាងស៊ី ចាត់ចំណាត់ថ្នាក់ទី២ បន្ទាប់ពីហុងកុង ។

ចំពោះការវិនិយោគរបស់ខេត្តក្វាងស៊ីទៅប្រទេសអាស៊ានវិញ ចាត់ចំណាត់ថ្នាក់ទី១ ។ ជាក់ស្តែងនៅក្នុងឆ្នាំ២០១១ ខេត្តក្វាងស៊ីបានបោះទុនវិនិយោគនៅអាស៊ានដែលមានទឹកប្រាក់១៧៥លានដុល្លាអាមេរិក កើនបាន ៧៣% ខ្ពស់ជាង ឆ្នាំ២០០៤ ដែលសំរេចបានតែ ៣,៧លានដុល្លាអាមេរិក ។

ប្រទេសដែលជាសមាជិកអាស៊ានដែលខេត្តក្វាងស៊ីទៅវិនិយោគមាន វៀតណាម ឥណ្ឌូនេស៊ី ឡាវ និងកម្ពុជា ។ ការវិនិយោគភាគច្រើនលើការស្រាវជ្រាវរ៉ែ ការកែច្នៃផលិតផលកសិកម្ម និងឧស្សាហកម្ម ធុនស្រាល ។ ដោយឡែកតាមការអះអាងរបស់មន្ត្រីជាន់ខ្ពស់សភាពាណិជ្ជកម្មខេត្តក្វាងស៊ីបានថ្លែងថា នៅក្នុងរយៈពេល៦ខែដើមឆ្នាំ២០១២នេះ ទំហំនៃការផ្លាស់ប្តូរពាណិជ្ជកម្ម **កម្ពុជា_ក្វាងស៊ី** កើនបាន ១១លានដុល្លាអាមេរិក ពោលគឺខ្ពស់ជាងឆ្នាំ២០១១ រយៈពេលដូចគ្នាដែលកើនបានតែ ២០%ប៉ុណ្ណោះ ។ លោក TanRui Xiang នាយករងរបស់សភាពាណិជ្ជកម្ម ខេត្តក្វាងស៊ីបានថ្លែងថា កម្ពុជានិងចិនជាមិត្តយូរអង្វែងនិងជាដៃគូនៃកិច្ចសហប្រតិបត្តិការពាណិជ្ជកម្មទ្វេភាគីកម្ពុជា-ចិន ដែលសំរេចបាន ២៥០០លានដុល្លាអាមេរិកនៅឆ្នាំ២០១១កន្លងទៅនេះ ។ ក្នុងនោះរវាង **ខេត្តក្វាងស៊ីនិងកម្ពុជា** អនុវត្តបាន ១៧លានដុល្លាអាមេរិក ស្មើនឹង៨៧% ខ្ពស់ជាងឆ្នាំ២០១០កន្លងទៅនេះ ។ វិស័យដែលផ្លាស់ប្តូរពាណិជ្ជកម្មរវាងខេត្តក្វាងស៊ីនិងកម្ពុជាមានផ្នែកកសិកម្ម ឧស្សាហកម្មកែច្នៃ អង្ករនិងការអភិវឌ្ឍន៍ធនធានធម្មជាតិ ។

សេចក្តីដូចបានជំរាបជូនខាងលើសូម **ឯកឧត្តមទេសរដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ប្រចាំខែតុលា ឆ្នាំ២០១២ ដោយអនុគ្រោះ ។

សូម **ឯកឧត្តមទេសរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំបាទ ។

ក្រុងណាននីង, ថ្ងៃទី 31 ខែតុលា ឆ្នាំ២០១២

**ទីប្រឹក្សាពាណិជ្ជកម្ម**

**អ៊ុច គឹមយ៉ុន**

<u>ចម្លងជូន</u>

-អគ្គកុងស៊ុលនៅណាននីង

-ឯកសារកាលប្បវត្តិ

Address: No 11, Zhujin Road, China-ASEAN Business District, Nanning City, Guangxi, China
Tel/Fax : +86-771-5389496
Email : clo_cambodia@yahoo.com